## តើអ្នកបានកត់សម្គាល់ឃើញការផ្លាស់ប្តូរទាំងនេះ ចំពោះនរណាម្នាក់ដែលអ្នកស្គាល់ ដែលមានអាយុចន្លោះពី 12 ដល់ 40 ឆ្នាំដែរឬទេ?

- មានអារម្មណ៍សង្ស័យ ឬភ័យខ្លាចចំពោះអ្នកដទៃ រួមទាំងមនុស្សដែលពួកគេធ្លាប់ជឿទុកចិត្តពីមុនផងដែរ
- ឮសំឡេង ឬសំឡេងនិយាយ មើលឃើញរូបភាព ឬមានអារម្មណ៍ចម្លែកៗ ដែលអ្នកដទៃមិនអាចយល់ឃើញ ឬទទួលអារម្មណ៍បាន
- អាកប្បកិរិយា ឬដំនើរចម្លែក និងមិនធម្មតា ដែលទើបកើតមានថ្មីៗ និងមិនមែនជាលក្ខណៈធម្មតារបស់បុគ្គលនោះ
- មានភាពងាយរងគន្ធិពលខ្លាំងជាងមុនចំពោះពន្លឺ សំឡេង ឬការប៉ះពាល់
- ពិបាកក្នុងការផ្តោតអារម្មណ៍ ការចងចាំ និងការយកចិត្តទុកដាក់
- ពិបាកក្នុងការប្រាស្រ័យទាក់ទងជាមួយ និងយល់ពីអ្នកដទៃ
- មានការលំបាកក្នុងការសិក្សា ឬការងារ ដែលទើបកើតមានថ្មី មានភាពធ្ងន់ធ្ងរ និងកាន់តែអាក្រក់ទៅៗ
- បាត់បង់ទំនាក់ទំនងសង្គម ឬឃ្លាតឆ្ងាយពីមិត្តភក្តិ និងក្រុមគ្រួសារ

**ប្រសិនបើដូច្នេះ ពួកគេអាចទទួលបានអត្ថប្រយោជន៍ពីការវាយតម្លៃបឋមដោយសម្ងាត់ ដោយបុគ្គលិក EPI-LA ដែលបានទទួលការបណ្តុះបណ្តាល ដើម្បីកំណត់ថាតើសេវាកម្មអន្តរាគមន៍ដំណាក់កាលដំបូងនៃជំងឺវិកលចរិត (Early Psychosis) អាចជួយពួកគេបានដែរឬទេ។ សូមផ្ញើអ៊ីមែលទៅក្រុម Early Psychosis របស់ DMH តាមអាសយដ្ឋានអ៊ីមែលៈ EarlyPsychosis@dmh.lacounty.gov**

## LACDMH ផ្តល់គុណតម្លៃ

**សុចរិតភាព។**
យើងប្រកាន់ខ្ជាប់នូវអាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ ស្របតាមស្តង់ដាសីលធម៌ខ្ពស់បំផុត។

**ការគោរព។** យើងទទួលស្គាល់នូវលក្ខណៈពិសេសរបស់បុគ្គលម្នាក់ៗ និងប្រព្រឹត្តចំពោះមនុស្សគ្រប់រូបដោយរបៀបដែលបញ្ជាក់ពីតម្លៃ និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់ពួកគេ។

**គណនេយ្យភាព។**
យើងទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់យើង និងលទ្ធផលដែលកើតចេញពីការសម្រេចចិត្តទាំងនោះ។

**កិច្ចសហការ។**
យើងធ្វើការរួមគ្នាដើម្បីសម្រេចបាននូវគោលដៅរួម ដោយសហការជាមួយសហគមន៍ទាំងមូល ចែករំលែកចំណេះដឹង កសាងការឯកភាពដ៏រឹងមាំ និងរួមចំណែកក្នុងការសម្រេចចិត្ត។

**ការប្តេជ្ញាចិត្ត។**
យើងនឹងខិតខំប្រឹងប្រែងគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់អតិថិជន និងសហគមន៍របស់យើង។

**តម្លាភាព។** យើងប្រាស្រ័យទាក់ទងដោយបើកចំហអំពីគំនិត ការសម្រេចចិត្ត និងលទ្ធផលរបស់យើង ដើម្បីធានាបាននូវទំនុកចិត្តលើអង្គភាពរបស់យើង។

**គុណភាព និង ឧត្តមភាព។** យើងកំណត់ស្តង់ដាបុគ្គល អង្គភាព វិជ្ជាជីវៈ និងគ្លីនិកខ្ពស់បំផុត ហើយប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវស្តង់ដាទាំងនោះដោយកែលម្អជាបន្តបន្ទាប់នូវគ្រប់ផ្នែកនៃការអនុវត្តរបស់យើង។

**ប្រសិនបើអ្នកកំពុងជួបវិបត្តិ ហើយត្រូវការជំនួយជាបន្ទាន់ សូមទូរស័ព្ទមកលេខឥតគិតថ្លៃ 24/7 របស់យើងខ្ញុំ ខ្សែទូរស័ព្ទជំនួយៈ 800.854.7771**

*បុគ្គលដែលមានពិការភាពថ្នែកការស្តាប់ ឬការនិយាយអាចទូរស័ព្ទទៅលេខ 711 ហើយស្នើសុំឱ្យប្រតិបត្តិការ ដែលនឹងបម្រើការជាអ្នកបកប្រែរវាងអ្នកហៅទូរស័ព្ទ និងបុគ្គលិករបស់យើង ទូរស័ព្ទទៅខ្សែជំនួយរបស់យើង។*

**សម្រាប់សំណួរទូទៅអំពីកម្មវិធី Los Angeles County EPI-LA សូមទាក់ទង EarlyPsychosis@dmh.lacounty.gov**



# កម្មវិធី EPI-LA សម្រាប់អន្តរាគមន៍ដំណាក់កាលដំបូងនៃជំងឺវិកលចរិត

*ពីមុនមានឈ្មោះថា កម្មវិធី PIER សម្រាប់អន្តរាគមន៍ដំណាក់កាលដំបូងនៃជំងឺវិកលចរិត*

LOS ANGELES COUNTY DEPARTMENT OF MENTAL HEALTH
hope. recovery. wellbeing.

## អំពីកម្មវិធី EPI-LA

ជំងឺវិកលចរិតត្រូវបានពិពណ៌នាថា ជាសំណុំអាកប្បកិរិយា
ឬការផ្លាស់ប្តូរផ្សេងៗដែលបុគ្គលម្នាក់ជួបប្រទះ
ដែលបង្ហាញថាពួកគេកំពុងមានការយល់ឃើញ
ឬបទពិសោធន៍អំពីការពិតខុសប្លែកពីធម្មតា។
នៅពេលដែលអាកប្បកិរិយា
និងការផ្លាស់ប្តូរទាំងនេះចាប់ផ្តើមកើតមានឡើង
ហើយប៉ះពាល់ដល់សមត្ថភាពរបស់បុគ្គលក្នុងការសម្រេច
គោលដៅជីវិតរបស់ពួកគេ
ពួកគេអាចទទួលបានអត្ថប្រយោជន៍ពីការគាំទ្រតាមរយៈ
កម្មវិធី EPI-LA របស់ LACDMH។

កម្មវិធី អន្តរាគមន៍ដំណាក់កាលដំបូងនៃជំងឺវិកលចរិត –
ឡូសអេនជឺលេស (Early Psychosis Intervention – Los
Angeles, EPI-LA)
ផ្តល់សេវាអន្តរាគមន៍ដំណាក់កាលដំបូងតាមរយៈ:
សេវាអ្នកជំងឺក្រៅ (Outpatient Services)
សម្រាប់បុគ្គលដែលមានអាយុចន្លោះពី 12 ដល់ 40 ឆ្នាំ
ដែលកំពុងមានសញ្ញា និងរោគសញ្ញាដំបូងនៃជំងឺវិកលចរិត
ឬដែលបានកើតមានរោគសញ្ញាវិកលចរិតជាលើកដំបូងក្នុ
ងអំឡុងពេល 5 ឆ្នាំចុងក្រោយ។
កម្មវិធីនេះមានគោលបំណងជួយអ្នកចូលរួមឱ្យសម្រេចគោ
លដៅជីវិតរបស់ខ្លួន
និងរៀនគ្រប់គ្រងរោគសញ្ញាដែលកំពុងជួបប្រទះ។ បុគ្គល
និងក្រុមគ្រួសាររបស់ពួកគេ ជាទូទៅទទួលបានសេវាកម្ម
និងការគាំទ្រពីកម្មវិធីនេះក្នុងរយៈពេលពី 2 ទៅ 5 ឆ្នាំ។

ដោយប្រើប្រាស់គំរូព្យាបាល Coordinated Specialty Care
(CSC សម្រាប់ FEP) កម្មវិធី EPI-LA ផ្តល់សេវាកម្មរួមមាន
ក្រុមគាំទ្រពហុគ្រួសារ (Multifamily Group)
ការព្យាបាលជាលក្ខណៈបុគ្គល សេវាថ្នាំព្យាបាល
ការគាំទ្រពីមិត្តភក្តិ និងឪពុកម្តាយ សេវាគាំទ្រផ្នែកអប់រំ
និងការងារ ព្រមទាំងការគ្រប់គ្រងករណី។ បុគ្គល
និងក្រុមគ្រួសារដែលពួកគេកំណត់ថាជាគ្រួសាររបស់ខ្លួន
នឹងរៀនអំពីរបៀបបង្កើនជំនាញក្នុងការដោះស្រាយបញ្ហា
រៀនវិធីគ្រប់គ្រងភាពតានតឹងដែលអាចបង្កឱ្យរោគសញ្ញាវិ
កលចរិតកើតឡើង
និងទទួលបានការគាំទ្រដែលពួកគេត្រូវការ
ដើម្បីបន្តដំណើរឆ្ពោះទៅសម្រេចគោលដៅជីវិតរបស់ខ្លួន។



## អ្នកផ្តល់សេវាកម្មកម្មវិធី EPI-LA

តំបន់សេវាកម្មទី 1 – Star View TEAMMATES
អ៊ីមែល៖ EPILA@starsinc.com
1216 West Avenue J, Suite 300
Lancaster, CA 93534
ទូរស័ព្ទ៖ (661) 341-3495

តំបន់សេវាកម្មទី 2 – SFVCMHC Inc.
អ៊ីមែល៖ EPI_LA@sfvcmhc.org
14535 Sherman Circle
Van Nuys, CA 91405
ទូរស័ព្ទ៖ (818) 901-4930

តំបន់សេវាកម្មទី 3 – IMCES
អ៊ីមែល៖ epi-la@imces.org
100 N. Barranca St. Suite 260
West Covina, CA 91791
ទូរស័ព្ទ៖ (626) 774-5060

តំបន់សេវាកម្មទី 4 – IMCES
អ៊ីមែល៖ epi-la@imces.org
3580 Wilshire Blvd., Suite 2000
Los Angeles, CA 90010
ទូរស័ព្ទ៖ (213) 381-1250

តំបន់សេវាកម្មទី 5 – The Help Group
អ៊ីមែល៖ EPI-LA@helpgroup.org
12099 Washington Blvd., Suite 200
Los Angeles, CA 90066
ទូរស័ព្ទ៖ (818) 288-0244

តំបន់សេវាកម្មទី 6 – The Help Group
អ៊ីមែល៖ EPI-LA@helpgroup.org
301 N. Prairie Ave., Suite 511
Inglewood, CA 90301
ទូរស័ព្ទ៖ (323) 291-5003

តំបន់សេវាកម្មទី 7 – The Whole Child
អ៊ីមែល៖ epila@thewholechild.org
10155 Colima Road
Whittier, CA 90603
ទូរស័ព្ទ៖ (562) 692-0383

តំបន់សេវាកម្មទី 8 – Star View TEAMMATES
អ៊ីមែល៖ EPILA@starsinc.com
649 E. Albertoni St., Suite 100
Carson, CA 90746
ទូរស័ព្ទ៖ (310) 436-9300

បានធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ 9/28/2026